ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី លី ច័ន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ទូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូច ចន្ថា
១២-មេធាវី ហួង គីមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណថុល
២០-មេធាវី យ៉ឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី ឃុត កែវសុត្ថា


លេខ ១០០១/គម/២១

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្តូរឈ្មោះក្រុមតេឡេក្រាមពី "ក្រុមជំនួយដល់មេធាវីក្នុងរយៈពេលបិទខ្ទប់" ទៅជា "សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)"

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជូនដំណឹងដល់សមាជិក-សមាជិកាគណៈមេធាវីមេត្តាជ្រាបថា គណៈមេធាវីបានចេញសេចក្តីសម្រេចលេខ ២៨៥/សសគម/២១ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការរបស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបង្កើតក្រុមតេឡេក្រាមផ្លូវការមួយដែលមានឈ្មោះថា "**សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)**" ដើម្បីបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ចែករំលែកព័ត៌មានវិជ្ជាជីវៈ ការជូនដំណឹងនិងការឆ្លើយតបរាល់បញ្ហារបស់សហភាតាប្រកបដោយភាពឆាប់រហ័ស ដល់សមាជិក-សមាជិកាគណៈមេធាវី។ កន្លងមកនេះ គណៈមេធាវីបានបង្កើតក្រុមតេឡេក្រាមមួយដែលមានឈ្មោះ "**ក្រុមជំនួយដល់មេធាវីក្នុងរយៈពេលបិទខ្ទប់**" ក្នុងគោលបំណងទទួលព័ត៌មាននិងជួយអន្តរាគមន៍ដល់មេធាវីក្នុងរយៈពេលបិទខ្ទប់ ដែលរហូតមកដល់ពេលនេះ ក្រុមតេឡេក្រាមនេះមានសមាជិកចំនួន ១ ៣៦៣នាក់។

យោងតាមស្ថានការណ៍និងភាពចាំបាច់នៃការងារ ដូច្នេះ គណៈមេធាវីសូមជូនដំណឹងដល់សមាជិក-សមាជិកាគណៈមេធាវីមេត្តាជ្រាបថា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ គណៈមេធាវីត្រូវប្តូរឈ្មោះក្រុមតេឡេក្រាមពី "**ក្រុមជំនួយដល់មេធាវីក្នុងរយៈពេលបិទខ្ទប់**"ទៅជា"**សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)**"វិញ ដើម្បីប្រើប្រាស់ក្នុងគោលបំណងដែលមានកំណត់ខាងលើ។

យោងតាមសេចក្តីសម្រេចលេខ ២៨៥/សសគម/២១ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ សមាជិក-សមាជិកាគណៈមេធាវីអាចប្រើប្រាស់ក្រុមតេឡេក្រាម "**សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)**" ដើម្បី៖

១.រាយការណ៍អំពី៖

- ភាពមិនប្រក្រតីនៃការប្រកបវិជ្ជាជីវៈ
- ភាពមិនប្រក្រតីនៃការបើកការិយាល័យ ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី
- ការប្រព្រឹត្តខុសវិធានវិជ្ជាជីវៈមេធាវី
- សកម្មភាពផ្សេងទៀតទាក់ទងនឹងការប្រកបវិជ្ជាជីវៈមេធាវី។

២.ស្នើសុំកិច្ចអន្តរាគមន៍ពីប្រធានគណៈមេធាវីក្នុងករណី៖

- មេធាវីដែលទទួលរងបណ្តឹង ត្រូវបានឃាត់ខ្លួនឬចាប់ខ្លួន ដោយសារការប្រកបវិជ្ជាជីវៈ



អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

- មេធាវីដែលត្រូវរងគ្រោះមកលើខ្លួនដោយសារការប្រកបវិជ្ជាជីវៈ
- ធ្វើអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ច ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រយោជន៍រួមរបស់វិជ្ជាជីវៈមេធាវី
- មេធាវីណាម្នាក់ដែលកំពុងជួបបញ្ហា។

៣.ចែករំលែកនូវព័ត៌មាន ឯកសារឬតំណភ្ជាប់ផ្សេងៗដែលមានលក្ខណៈជាការផ្តល់ចំណេះដឹងនិងបទពិសោធន៍។

៤.លើកអំពីបញ្ហាប្រឈម ចម្ងល់ឬយោបល់ទូទៅអំពីច្បាប់ឬលិខិតបទដ្ឋានគតិយុត្តិសម្រាប់ជាធាតុចូលដល់គណៈមេធាវីក្នុងការរៀបចំជាសេចក្តីសម្រេច សេចក្តីណែនាំ ការពន្យល់ឬដំណោះស្រាយ ជូនសមាជិក-សមាជិកាក្នុងការតម្រង់ទិសដល់ការប្រកបវិជ្ជាជីវៈមេធាវីឱ្យបានត្រឹមត្រូវទៅតាមការកំណត់របស់គតិច្បាប់។

៥.បញ្ជូនយោបល់ឬសំណូមពរនានារបស់ខ្លួនសម្រាប់មហាសន្និបាតប្រចាំឆ្នាំ តាមការកំណត់របស់គណៈមេធាវី។

៦.សមាជិក-សមាជិកាដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោតប្រធានឬក្រុមប្រឹក្សាគណៈមេធាវី អាចធ្វើសកម្មភាពឃោសនារបស់ខ្លួនបាន ដោយអនុលោមតាមបញ្ញត្តិនៃការឃោសនាបោះឆ្នោត។

គណៈគ្រប់គ្រងក្រុមតេឡេក្រាមនេះ ក៏បានដាក់ចេញនូវក្រមសីលធម៌ដែលសមាជិក-សមាជិកាគណៈមេធាវីត្រូវគោរពផងដែរ។

អាស្រ័យហេតុនេះ សូមសមាជិក-សមាជិកាគណៈមេធាវីជ្រាបជាព័ត៌មាន។

ឆ្លៀតក្នុងឱកាសនេះ គណៈមេធាវីនៅតែសូមអំពាវនាវដល់សមាជិក-សមាជិកាគណៈមេធាវីមេត្តាបន្តគោរពនិងអនុវត្តតាមវិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក៏ដូចជា**វិធានការ ៣ កុំ និង ៣ ការពារ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យបានខ្ជាប់ខ្ជួន។

ថ្ងៃពុធ ១៤ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២១

**ប្រធានគណៈមេធាវី**

មេធាវី លី ច័ន្ទតុលា